# ព្រះរាជជីវប្រវត្តិ



## សម្ដេចព្រះមហាសង្ឃរាជា និល ទៀង
## គណៈមហានិកាយ

គង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ

៥០០០ឆ្នាំ

www.5000-years.org

# ក្រុងកម្ពុជាធិបតី

## ព្រះរាជប្រវត្តបុព្វចរិយា
## បុណ្យសម្ភោធព្រះរូប សម្តេចព្រះសង្ឃរាជ សង្ឃនាយកព្រះនាម និល ទៀង

ដកស្រង់ចេញពីសាស្ត្រា
នៅបណ្ណាល័យ វត្តសារាវ័ន

FEMC
a 92

1/1

អតីតសាស្ត្រាចារ្យមធ្យមសិក្សា
អក្សាសិទ្ធិ

លី សុធីរ

# ប្រវត្តិសង្ខេប



## លី សុវីរ

**លី សុវីរ** កើតនៅថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំរោងព.ស.២៤៧២ ត្រូវ នឹង ថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩២៨ នៅភូមិឫស្សីធ្នង់ ឃុំបឹងព្រះស្រុកបាភ្នំ ខេត្តព្រៃវែង ឪពុកព្រះនាម **លី អែម** ម្ដាយព្រះនាម **ខិន ខ៉ាន់**។

ពីអាយុ ១ឆ្នាំ រហូតដល់អាយុ ២០ឆ្នាំ នៅជាមួយឪពុកម្ដាយខំរកស៊ីបំរើឪពុកម្ដាយ គ្មានបានរៀនសូត្រអ្វីទាំងអស់។ លុះដល់អាយុ២១ឆ្នាំ ឪពុកម្ដាយបានអនុញ្ញាតអោយបួសរៀននៅវត្តសិរីមង្គល ហៅព្រៃវាយ ដែលជាវត្តកេរដំនែលពីឪពុក ស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកបាភ្នំ ខេត្រព្រៃវែង បួសនៅក្នុងសំនាក់ព្រះតេជព្រះគុណ គង់ យី ជាព្រះឧបជ្ឈាយ៍, ព្រះតេជព្រះគុណ លី អ៊ុម ជាឧបសម្បទាចារ្យ។

លុះដល់អាយុ ២២ឆ្នាំ បានចេញទៅរៀនភាសាបាលី នៅវត្តព្រៃទំពូង, វត្តព្រែកចង្ក្រានលើ, វត្តសារាវ័ន, វត្តឧណ្ណាលោម។ នៅក្នុងគ.ស.១៩៥៦ បានប្រលងជាប់ចូលរៀន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។ លុះដល់គ.ស.១៩៦៦បានប្រលងបញ្ចប់បរិញ្ញាប័ត្រទស្សនវិជ្ជាសាសនា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។

ពេលលាចាកសិក្ខាបទ នៅឆ្នាំ ១៩៦៦ បានធ្វើជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ឆ្នាំ បានធ្វើការនៅសូណាព្រីម ២ឆ្នាំ។

នៅឆ្នាំ ១៩៦៧ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ឡាយ ប៊ុនណា នៅភូមិព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានកូនស្រី ៤នាក់ និងកូនប្រុស ៣នាក់។ បច្ចុប្បន្នស្លាប់អស់ ២នាក់ នៅរស់កូនស្រី ៣នាក់ និងកូនប្រុស ២នាក់។

នៅឆ្នាំ ១៩៦៩ បានធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យសិរីមង្គល (រកាកោង)។ នៅឆ្នាំ ១៩៧២ ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរអង់គ្លេស (បឹងត្របែក)។ នៅឆ្នាំ ១៩៧៥ ទៅនៅស្រុកកំណើត។ នៅឆ្នាំ ១៩៧៩ ធ្វើគ្រូនៅសាលាបឋមសិក្សាវត្តបឹងព្រះ។ នៅឆ្នាំ ១៩៨០ធ្វើជាអ្នកនិពន្ធសៀវភៅសិក្សានៅក្រសួងអប់រំ។ នៅឆ្នាំ ១៩៩៧ ខែតុលា ចូលនិវត្តន៍។

ភ្នំពេញ, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤

**លី សុធីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធ

# អារម្ភកថា

ខ្ញុំយល់ថា ប្រជានុរាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល មានប្រជានុរាស្ត្រចំនួន ៩៥% ជាអ្នកកាន់ព្រះពុទ្ធសាសនា, មានចំនួន ៤0% ជាអ្នកបានរៀនច្បាប់ព្រះពុទ្ធសាសនា ។ តែនៅសម័យបច្ចុប្បន្ននេះ មានការខ្វះឯកសារផ្សេងៗ ជាពិសេសច្បាប់ដែលត្រូវសិក្សាពីព្រះពុទ្ធសាសនា និងប្រវត្តិផ្សេងៗ ដែលបាននិយាយពីប្រវត្តិអ្នកប្រាជ្ញខ្មែរខាងព្រះពុទ្ធសាសនា ។

ដូចនេះ ខ្ញុំនឹងខំពិព្យាយាមប្រមែប្រមូលឯកសារនានា ដែលបាននិយាយពីព្រះរាជជីវប្រវត្តិ និងប្រវត្តិ នៃសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក និងព្រះសង្ឃនាយក នៃគណៈមហានិកាយ និងធម្មយុត្តិកនិកាយ ។

នៅបច្ចុប្បន្ននេះ ខ្ញុំបានរៀបចំព្រះរាជជីវប្រវត្តិ នៃសម្តេចព្រះមហាសង្ឃរាជា និល ទៀង ដែលបានជាសម្តេចព្រះសង្ឃរាជមុនគេនៃព្រះសង្ឃគណៈមហានិកាយ ។ ព្រះរាជជីវប្រវត្តិនៃសម្តេចព្រះមហាសង្ឃរាជា និល ទៀង នេះ ខ្ញុំមាន ៣ច្បាប់ ។ តែឯកសារទាំង៣ច្បាប់នេះ មានលក្ខណៈមិនដូចគ្នាទេ តែងមានលក្ខណៈផ្សេងគ្នាជាលំដាប់ ។

ខ្ញុំបានយកឯកសារមួយដែលមានអាយុច្រើនជាងគេ ហើយនៅសម័យបច្ចុប្បន្ននេះ មាននៅជាសាស្ត្រានៅឡើយ មកចំលងបោះពុម្ពចែកជូន

ជាបណ្ដើរ ព្រោះ ឯកសារនេះ ក្មួយៗ នៅក្មេងក៏មិនអាចមើលបានផង ។
សូមជួយទិទៀនស្ដាបនា ដោយអនុគ្រោះ ។

លី សុវីរ

# ព្រះរាជជីវប្រវត្តិ
# ព្រះមហាសង្ឃរាជា ព្រះនាមទៀង

សុភមស្តុ ព្រះពុទ្ធសករាជព្រះសាសនា កន្លងទៅបាន ២៤៥៧ ព្រះវស្សា មហាសករាជ ១៨៣៦ ចុល្លសករាជ ១២៧៦ អាត្មាភាព ព្រះវនរត្ន វិភទ្ធញ្ញាណ បវរបរិនាយក សូមថ្វាយព្រះពរ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិបតី ព្រះករុណាជាអម្ចាស់ជីវិត សូមចំរើនពរ លោក ឡឺរ៉េស៊ីដង់ សុប៉េរិយើ ជាធំ និងព្រះរាជវង្សានុវង្ស និងកុង្សិសេនាបតី នាម៉ឺនសព្វមុខមន្ត្រី និងទាយក ទាយិកា និងព្រះរាជាគណ ឋានានុក្រមសង្ឃ ដែលមកសន្និបាត ប្រជុំក្នុងពិធីបុណ្យសម្ពោធព្រះរូប រំលឹកព្រះតេជព្រះគុណ ព្រះបារមីសម្តេចព្រះមហាសង្ឃរាជា ក្នុងព្រះគោត្តព្រះនាម ទៀង ជាអ្នក ប្រាជ្ញធំឧត្តមប្រសើរក្នុងបច្ចុប្បន្ននេះ មានគុណបំនាច់ជាធំបំផុតនេះ ។

អាត្មាភាពព្រមទាំងព្រះរាជាគណ ឋានានុក្រមសង្ឃ សូមអំនរព្រះគុណ ជាច្រើនពន់ប្រមាណ អាត្មាភាពសូមអធិប្បាយតាមព្រះរាជប្រវត្តិបុព្វចរិយា ដែលព្រះអង្គប្រព្រឹត្តអោយឃើញច្បាស់ជាក់ប្រាកដ ។

កាលព្រះវស្សា ៨ឆ្នាំ ជាប់ហៃព្រះបាទ សម្តេចព្រះហរិរាមាឥស្សរាធិបតី កាលនៅជាព្រះអង្គម្ចាស់ អង្គដួង ទៅនៅស្រុកមង្គលបុរី លុះដល់ព្រះជន្ម

១១ឆ្នាំ នាយពៅជាមាននាំទៅក្រុង បាងកក ផ្ញើទុកនឹងសម្តេចចៅ ទីសម្តេចព្រះធម្មកោសា ក្នុងផែនដីព្រះឡិតឡា ហើយសម្តេចព្រះធម្មកោសា បានបំបួសជាសាមណេរ ហើយប្រៀនប្រដៅព្រះបរិយត្តិធម៌ បានដូចព្រះទ័យ ។

លុះដល់ផែនដីព្រះណាំងក្លាវ ធ្វើបុណ្យព្រះមេរុកណ្តាលព្រះនគរ ។ សម្តេចព្រះធម្មកោសា អោយសាមណេរ ទៀង នាំព្រះសង្ឃក្នុងក្រុងបន្ទាយពេជ្ជ ទៅថ្វាយសត្តបករណ៍ ព្រះណាំងក្លាវទ្រង់ជ្រាបច្បាស់ថា ជាអ្នកប្រាជ្ញប្រាកដមែន ពីថ្ងៃនោះរៀងមក ទ្រង់មានព្រះរាជមេត្រី ។

លុះដល់សាមណេរ ទៀង បានព្រះវស្សា ២១វស្សា ព្រះណាំងក្លាវទ្រង់ព្រះរាជានុញ្ញាតអោយចូលបួសនាគខាន់ហ្លួង នៅវត្តព្រះស្រីរតនសាស្តារាម គឺវត្តព្រះកែវមរកត បានឧបសម្បទាជាភិក្ខុភាវៈ ហើយអាចារ្យ ទៀង មានក្តីពិព្យាយាមធំ និងប្រៀនប្រដៅព្រះបរិយត្តិធម៌ ដល់សិស្សានុសិស្ស និងជាបរិយត្តិធម៌មិនបានឈប់ ជាធម៌បីតិសំរាន្តព្រះទ័យ នៅក្នុងក្រុងបាងកក ។

លុះដល់ព្រះជន្មវស្សា ២៥ឆ្នាំវស្សា បានចូលថ្វាយព្រះពរ លាព្រះចៅណាំងក្លាវ ។ ព្រះចៅណាំងក្លាវ ទ្រង់ព្រះរាជានុញ្ញាតអោយជូនតាមរយៈផ្លូវដរាបមកដល់ស្រុកខ្មែរ ។ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គដួង ទ្រង់ឈ្វេងដោយព្រះទ័យជាសាសនូបត្ថម្ភ ដើម្បីនឹងញ៉ាំងព្រះបរិយត្តិ អោយថ្កើងរុងរឿងក្រុងកម្ពុជាធិបតី ទ្រង់ជ្រាបថា ព្រះអាចារ្យ

ទៀង នេះចេះមុតប្រាកដទាំងគន្ថធុរៈ វិបស្សនាធុរៈ ហើយទ្រង់មានព្រះរាជមេត្រីព្រះអាចារ្យ ទៀង ជាទីបំផុត ។

លុះដល់ព្រះអាចារ្យ ទៀង ចូលទៅថ្វាយព្រះពរលា ទ្រង់ឃាត់មិនអោយទៅបាងកកវិញ ទ្រង់អោយនៅវត្តប្រាង្គ ហើយទ្រង់មានសព្វអក្សរទៅសុំដល់ព្រះចៅណាំងក្លាវ ។ ព្រះចៅណាំងក្លាវ ទ្រង់អនុញ្ញាតតាមអធ្យាស្រ័យ ។ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ទ្រង់តាំងព្រះអាចារ្យ ទៀង អោយឡើងព្រះអរិយវង្ស ឡើងពីទីអរិយវង្ស ជាព្រះធម្មឧត្តម, ឡើងពីទីព្រះធម្មឧត្តម ជាព្រះមហាវិមលធម្ម ឡើងពីទីព្រះមហាវិមលធម្ម ជាទីព្រះមហាព្រហ្មមុនីបាន៤ខែ នោះព្រះជន្មវស្សាបាន១៤ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ទ្រង់ព្រះមេត្តាប្រោសអោយគ្រងទី សម្តេចព្រះសង្ឃរាជា នៅក្រុងឧដុង្គមានជ័យ គង់នៅវត្តប្រាង្គដល់ព្រះជន្មវស្សា ៣៥ឆ្នាំ វស្សាបាន១៥ឆ្នាំ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ទ្រង់តាំងពេញទីជាសម្តេចព្រះមហាសង្ឃរាជា សង្ឃនាយក ។ ទ្រង់បានធ្វើរាជការថ្វាយ សម្តេចព្រះហរិរក្ស ជាអធិបតីក្នុងប្រយោគ អោយភិក្ខុសាមណេរ ប្រែព្រះបរិយត្តិប្រយោគ និងសម្តេចព្រះសុគន្ធាធិបតី ប៉ុន្តែមិនតែរាជការបដិបត្តិបូជា ក្នុងរាជការ អាមិសបូជា ក៏ព្រះរាជានុញ្ញាតអោយធ្វើស្នងព្រះអង្គទាំងអស់ ។

លុះដល់រាជ្យសម្តេចព្រះនរោត្តម ក៏ទ្រង់ប្រារព្ធរឿងព្រះពុទ្ធសាសនា នឹងសម្តេចព្រះសង្ឃរាជា រួមនឹងសម្តេចព្រះសុគន្ធាធិបតី អំពីពិធីដេញប្រយោគ នៅក្នុងក្រុងឧដុង្គមានជ័យម្តង ។ លុះដល់ព្រះនរោត្តម ទ្រង់ស្តេចយាងមកគង់នៅក្នុងក្រុងភ្នំពេញ ដល់ធ្វើបុណ្យមេរុ សម្តេចព្រះមាតុច្ឆាទ្រង់ប្រារព្ធរាជពិធីដេញប្រយោគព្រះបរិយត្តិម្តងទៀតជាគំរប់ពីរដង រួមនឹងសម្តេចទាំងពីរព្រះអង្គ ។ កាលសម្តេចព្រះនរោត្តម ទ្រង់សាងឧបោសថាគាររតនារាម ។ ទ្រង់ព្រះរាជានុញ្ញាតរាជការនោះ ថ្វាយសម្តេចព្រះមហាសង្ឃរាជា លុះស្រេចហើយ ទ្រង់ថ្វាយព្រះពរ សម្តេចព្រះនរោត្តមរឿងចងនិមិត្តសីមាជាថាវរកម្ម មាំក្នុងព្រះពុទ្ធសាសនា រំលងអំពីនោះមកព្រះបាទសម្តេចព្រះនរោត្តម ទ្រង់សាងព្រះវិហារហិរញ្ញរាជនិការាម ក្នុងក្រុងឧដុង្គមានជ័យ ទ្រង់ព្រះរាជានុញ្ញាតរាជការនោះមក សម្តេចព្រះមហាសង្ឃរាជាទ្រង់ចាត់ចែងសាងព្រះវិហារនោះស្រេច ហើយចងនិមិត្តសីមាជាស្រេចទៀត ។

លុះមកដល់ព្រះបាទព្រះស៊ីសុវត្ថិព្រះចៅក្រុងកម្ពុជាធិបតី ព្រះករុណាជាម្ចាស់ជីវិតសព្វថ្ងៃនេះ ទ្រង់ថ្វាយព្រះពរពីព្រះរាជបណ្តាំ ព្រះវររាជបិតា ថានឹងកសាងព្រះប្រាង្គនៅក្រុងឧដុង្គមានជ័យ នោះព្រះករុណាក៏ទ្រង់យល់តាមសម្តេចព្រះមហាសង្ឃរាជា ។ ព្រះសង្ឃរាជាទ្រង់ទទួលរាជការសាងព្រះប្រាង្គនោះនឹងព្រះអង្គ លុះតែរាជការនោះស្រេច ហើយទ្រង់ថ្វាយព្រះពរ

ព្រះករុណាថា ព្រះប្រាង្គនេះ ព្រះរាជបំនងធ្វើ ដើម្បីនឹងតំកល់ព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ដែលបានពីលង្កាទ្វីប ។ នោះព្រះករុណាទ្រង់តាមសម្តេច ព្រះមហាសង្ឃរាជា ហើយទ្រង់ចាត់ក្បួនហែព្រះបរមសារីរិកធាតុតាមផ្លូវនានា អំពីក្រុងភ្នំពេញទៅដល់កំពង់ហ្លួង ទ្រង់ចាត់ក្បួនហែតាមផ្លូវជើងគោក ទៅដល់វត្តប្រាង្គ ហើយរៀបព្រះសារីរិកធាតុតំកល់លើព្រះប្រាង្គ ធ្វើបុណ្យសម្ពោធឆ្លង ។ លុះដល់គ្រាក្រោយទៀត ព្រះករុណាទ្រង់ប្រារព្ធនិងបដិសង្ខរណៈ ជួសជុលព្រះវិហារអដ្ឋរស្ស ហើយទ្រង់ថ្វាយរាជការនោះមកសម្តេចព្រះមហាសង្ឃរាជា ទ្រង់ចេញព្រះរាជប្រកាស ឃោសនាអស់អ្នកនគរបានជាបច្ច័យទាន លម្មបដិសង្ខរណៈបាន ទ្រង់ថ្វាយព្រះពរព្រះករុណា សូមព្រះរាជានុញ្ញាត សូមហត្ថកម្ម ព្រះករុណាអនុញ្ញាតតាមការ ។

លុះដល់ការបដិសង្ខរណៈស្រេច ហើយទ្រង់ថ្វាយព្រះពរ អំពីចងនិមិត្តសីមាថ្វាយ ។ លុះគ្រាជាងក្រោយទៀត សម្តេចទ្រង់ថ្វាយព្រះពរព្រះករុណាពីរឿងព្រះរាជពិធី ដេញប្រយោគព្រះបរិយត្តិ ព្រះករុណាទ្រង់ថ្វាយព្រះរាជា-នុញ្ញាតតាមព្រះអធ្យាស្រ័យ សម្តេចទ្រង់ចេញរាជប្រកាស ឃោសនាអស់អ្នកនគរបានជាបច្ច័យ នឹងរៀបពិធីដេញជាប្រយោគបាន ទ្រង់ថ្វាយព្រះករុណាសូមព្រះរាជកំនត់នក្ខត្តឫក្ស និងឧបោសថាគាររតនារាមជាទីរៀបពិធី ប្រែព្រះបរិយត្តិប្រយោគ ។ សម្តេចទ្រង់រៀបពិធីនេះ ថ្វាយព្រះរាជកុសលជា

រាជការបំផុតខាងក្រោយ ហើយព្រះរោគក៏ប្រឈួនដល់ព្រះអង្គ ដោយទ្រង់ព្រះជរា ក្នុងព្រះជន្មវស្សាគំរប់ ៩០គត់ ។

ក្នុងសម័យដែលទ្រង់ប្រឈួននោះ ទ្រង់មានព្រះបន្ទូល នឹងព្រះវនរត្នចន្ទប្រារព្ធរឿងសិតព្រះរូបតំនាងព្រះអង្គ ជាចារីកទុកក្នុងព្រះពុទ្ធសាសនា ។ នោះព្រះវនរត្ន ក៏ទទួលការសិតព្រះរូប តាមព្រះរាជបំនងហើយរាជាគណ បាំនានុក្រមសង្ឃទាំងពួង ក្នុងក្រុង ក្រៅក្រុង អោយដឹងទូទៅទាំងអស់ ព្រះរោគដែលប្រឈួនក្នុងព្រះអង្គនោះ ក៏ពុំសះស្បើយ រឹតតែមានកំលាំងឡើង ទ្រង់សោយព្រះវិមុត្តិធម៌ទិវង្គត នៅថ្ងៃព្រហស្បតិ៍ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ បញ្ចស័ក ត្រូវនឹងថ្ងៃទី ២ ខែ ឧកតូប្រ៏ ឆ្នាំ១៩១៣ ក្នុងវេលាម៉ោង១២មីនុត៤០ ឯដាស់ទុំ ដល់ថ្ងៃព្រហស្បតិ៍ ៨កើត ខែកត្តិក ឆ្នាំឆ្លូវបញ្ចស័ក ត្រូវនឹងថ្ងៃ ៦ ខែណូវែមប្រ៏ ឆ្នាំ១៩១៣ ។

ព្រះវនរត្ន និងព្រះរាជាគណ បាំនានុក្រមសង្ឃ និងសិស្សានុសិស្ស រៀបពិធីសិតព្រះរូប ក៏បានសំរេចដូចសេចក្តីប្រាថ្នា អស់យើងរាល់គ្នា ជាការស្រេចតាមព្រះរាជបំនង ។ សម្តេចព្រះសង្ឃរាជាព្រះនាម ទៀង នេះដែលទ្រង់ប្រារព្ធអោយសិតព្រះរូបជាចារីក ទុកក្នុងព្រះពុទ្ធសាសនាគួរណាស់ ព្រោះព្រះអង្គជាកំពូលអ្នកប្រាជ្ញក្នុងបច្ចុប្បន្ននេះ ទ្រង់ជ្រាបច្បាស់ទាំងគតិលោក និងគតិធម៌ អក្សរ សំស្រ្កឹត និងបាលី និងពាក្យខេមរៈ និងព្រះរាជពង្សាវតារ

និងសេចក្ដីពីបុរាណផ្សេងៗ និងអត្ថវិមុត្តិសម្បូណ៌រាជនីតិ ទាំងអគារ និងអនាគារវិន័យផ្លូវប្រតិបត្តិ ឧបាសក ឧបាសិកា ភិក្ខុ សាមណេរ ហើយទ្រង់ឧស្សាហ៍ និងទរមាន រំលឹកសតិបញ្ញាអោយភ្លឺស្វាង ក្នុងផ្លូវប្រតិបត្តិនោះ ទោះបីប្រទេសណាងឿងឆ្ងល់ ពីរឿងផ្លូវសាសនា ហើយបង្គំទូលសួរ ទ្រង់ព្រះរាជទានសេចក្ដីអធិប្បាយ ញុំាំងអោយអ្នកប្រទេសនោះ ទុកចិត្តជឿផ្លូវសាសនាបាន ។ ព្រះរាជហឫទ័យក៏ល្អ ព្រះកិត្តិយសល្បីលឺទូទៅគ្រប់ប្រទេសនានា សឹងចូលមកដល់ ហើយចង់ចូលមកក្រាបបង្គំគាល់ ជាព្រះរាជមេត្រីរាជការប្រូតិកតូរ៉ាដែលទំនុកបំរុងក្រុងកម្ពុជា ។ ក្រុងកម្ពុជាធិបតីក៏ថ្វាយគ្រឿងឥស្សរិយយស ដោយមានគុណបំនាច់ និងផែនដីរាជការយល់ប្រាកដថាជាអ្នកប្រាជ្ញធំ ក្នុងក្រុងកម្ពុជា ហើយមានព្រះរាជមេត្រីជាម៉ាំ យើងទាំងពួងរាល់គ្នា ក៏បានឃើញប្រាកដមែន ។ ក្នុងសម័យថ្ងៃសុក្រ ១០រោច ខែអាសាធ ឆ្នាំខាល ឆស័ក ត្រូវនឹងថ្ងៃ១៧ ខែ សូយ៉េក ឆ្នាំ១៩១៤ នេះជាថ្ងៃមង្គលរឹកមានជោគជ័យសួស្តី ជួបជុំធ្វើបុណ្យសម្ពោធព្រះរូបសម្មតិថាជា ព្រះរូបសម្តេចព្រះមហាសង្ឃរាជា ជាព្រះសង្ឃនាយក ក្នុងក្រុងកម្ពុជា សូមសេចក្ដីវឌ្ឍនាការចំរើនថ្វាយដល់លោកឡឺរេស៊ីដង់ សុប៉េរិយើ និងអ្នករាជការបារាំងសេសជាមហានគរធំ និងក្រុងកម្ពុជាធិបតី សូមអោយគង់ជាស្ពានមេត្រីស្ថិតស្ថេរចិរកាលអោយបានរុងរឿង ជាសិរីសុខាមហាប្រសើរតទៅ និងព្រះរាជាគណ

ឋានានុក្រមសង្ឃ និងព្រះរាជវង្សានុវង្ស អង្គអគ្គមហាសេនាបតី នាម៉ឺនសព្វមុខមន្ត្រី អាណាប្រជានុរាស្ត្រ មានអ្នកដែលបានចូលប្រាក់ ចូលគំនិតនិងកំលាំងជាដើម សូមអោយចំរើនមគ្គ និងផល ក្នុងព្រះពុទ្ធសាសនាជួយទ្រទ្រង់អោយបានជួបសេចក្ដីប្រាថ្នា ទាំងលោកិយ និងលោកុត្តរតទៅ អោយកាន់តែមានចិត្តប្រតិបត្តិ ក្នុងព្រះពុទ្ធសាសនា អោយចំរើនឡើងតរៀងទៅតាមព្រះពុទ្ធបញ្ញត្តិ ដោយសត្យានុសត្យ ជាប្រាកដទៅអនាគតហោង ។

សូមទ្រង់ព្រះមេត្តាប្រោស សូមជំរាបក្នុងវេលាគ្រាដែលរាជាភិសេកព្រះរូបសម្ដេចព្រះសង្ឃរាជាគណាធិបតីនេះ មានទ្រង់ព្រះករុណាព្រះចៅក្រុងកម្ពុជាធិបតី ជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងព្រះរាជវង្សានុវង្ស ហើយនឹងអស់លោកដែលមានបណ្ដាសក្តិធំៗ ស្ដេចអញ្ជើញមកសន្និបាតជួបជុំ នោះខ្ញុំសូមប្រកាសតាំងនាមបារាំងសែស ជាទីសត្យាគោរពដល់ព្រះកិត្តិយសនៃសម្ដេចព្រះមហាសង្ឃរាជាគណាធិបតី កាលទ្រង់គង់ព្រះជន្មនៅឡើយនោះទ្រង់ប្រគល់ដោយនៅគុណធម៌ដ៏ប្រសើរអស្ចារ្យ ហើយព្រះវិជ្ជាក៏ជ្រៅជ្រះទូលាយរុងរឿងឡើងជាអ្នកប្រាជ្ញធំ តាំងអំពីព្រះជន្មគំរប់ ៣៥ព្រះវស្សា បានអភិសេកឡើងជា "**សម្ដេចព្រះមហាសង្ឃរាជាគណាធិបតី សិរីបរមបពិត្រជាសង្ឃនាយកតិលកលោកាចរិយោត្តមបរមមេធសង្ឃជេដ្ឋាមហាសង្ឃរាជាធម្មិកទសរោត្តម បរមបពិត្រ ដ៏ជាអធិបតីពុទ្ធដ៏គណសង្ឃ**

**ក្នុងក្រុងកម្ពុជារដ្ឋាមហាឥន្ទបត្តនគរបវរបុរីរម្យឧត្តមរាជធានី មហាមគ្គនាយក**" សំរេចសង្ឃកិច្ចអស់ទ្រទ្រង់សង្ឃរាជាគណ ទាំងបួនសំរាប់ ។ នោះទ្រង់តែងតែមានព្រះរាជហឫទ័យខ្វល់ខ្វាយផ្សាយ នូវការកុសលជាទីចំរើនដល់ក្រុងកម្ពុជាធិបតី បង្កើតវិហារាមឧបោសថថ្មី ហើយនឹងបានជួសជុលថមថែមរក្សាវត្តចាស់ដ៏ច្រើន នេះក៏ដោយសារតែព្រះតេជព្រះគុណ ដែលទ្រង់ព្រះឧស្សាហ៍ពិព្យាយាមពុំដែលដាច់ ។ មួយទៀត ទ្រង់បានចាត់ចែងចំរើនក្នុងការសិក្សាធិការរៀបអោយប្រលងចំនេះធៀបប្រយោគអ្នករៀនមានជាបីយ៉ាង បានកើតជាការដូចសេចក្ដីប្រាថ្នាដ៏ប្រសើរថ្កើងរុងរឿង ។

នៅវេលាជាន់ក្រោយបង្អស់នេះ ទ្រង់មានព្រះព្យាយាម យកព្រះរាជហឫទ័យ ដាក់ទុកជួយទំនុកបំរុងរាជការប្រួតិកត្ញ៉ា នៅវេលាបែររៀបចាត់ចែងតែងអោយមានបង្រៀនជារបៀបសិក្សាធិការគ្រប់វត្ត ។ មួយទៀតក្នុងខណៈនេះ ខ្ញុំក៏នៅរំលឹកនឹកដល់ព្រះកេរ្តិ៍ព្រះសពពីនេះ សម្ដេចកាលស្ដេចគង់ព្រះជន្មនៅឡើយនោះ ទ្រង់តែងតែមានព្រះសត្យានុសត្យស៊ូទៀងត្រង់នឹងរាជការបារាំងសែស ដោយស្មោះអស់ពីព្រះរាជហឫទ័យ ក្នុងរវាង៥០ឆ្នាំជាកំលុង ដែលទ្រង់បុណ្យព្រះសង្ឃនាយកនោះ ទ្រង់តែងតែជួយកាន់ការពារខាងរាជការបារាំងសែស ដើម្បីនឹងធ្វើរាជការ អោយបានក្រុងកម្ពុជាធំទូលាយថ្កើងរុងរឿងដូចនេះ ។

ហេតុនេះខ្ញុំសូមគំនាប់ដោយគោរព ដល់ព្រះកេរខេមរជាតិ ដែលមានត្រកូលធំនេះ ហើយដែលបានជាមិត្រ មានចិត្តស្មោះទៀងត្រង់ នឹងរាជការបារាំងសែសនោះផង ។

**អតីតសាស្ត្រាចារ្យមធ្យមសិក្សា**
**អក្សរសិទ្ធិ**

**លី សុទីរ**

រោងពុម្ព វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ